# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ


**អគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

លេខ: ៣២៩៣ សជណ.ទទក.មទទជ


ថ្ងៃ ព្រ ០១ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណៈជនឲ្យបានជ្រាបថា ក្រោមការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ **រាជរដ្ឋាភិបាលកម្ពុជា** មានឆន្ទៈជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនី-ភាវូបនីយកម្មជនបទ (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត **"កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ"**។ កម្មវិធីនេះជាកម្មវិធីអនុវត្តពីឆ្នាំ២០១៣ និងបន្តអនុវត្តក្នុងឆ្នាំ២០២៤។ គោលបំណងនៃកម្មវិធី គឺជួយដល់គ្រួសារក្រីក្រនៅតំបន់ជនបទ អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណចូលផ្ទះគ្រួសារជនបទ។ ក្រោមកម្មវិធីនេះ ម.អ.ជ. ផ្តល់សម្ភារអគ្គិសនីក្នុងផ្ទះ និងខ្សែបណ្តាញពីនាឡិកាស្ទង់ដល់ផ្ទះសម្រាប់ការតភ្ជាប់ចរន្តជាអំណោយ ហើយគ្រួសារជនបទត្រូវទទួលបន្ទុកទូទាត់ចំណាយលើការបង់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី ឈ្នួលពលកម្មរៀបចំខ្សែបណ្តាញពីនាឡិកាស្ទង់ដល់ផ្ទះ និងឈ្នួលពលកម្មរៀបចំសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

ដើម្បីឲ្យកម្មវិធីនេះអនុវត្តន៍ទៅមានប្រសិទ្ធភាពខ្ពស់ សូមលោក/លោកស្រីដែលជាម្ចាស់អាជ្ញាបណ្ណត្រូវស្រង់ពីតួលេខនៃលំនៅដ្ឋានគ្រួសារក្រីក្រ និងផ្តល់ចំណុចអាប់ស៊ីស (X) និងចំណុចអរដោណេ (Y) ទីតាំងភូមិសាស្ត្រ (WGS 1984) ដើម្បីពិនិត្យ និងផ្តល់ជូន។ ព័ត៌មានលំអិតសូមចូល www.ref.gov.kh និងឈ្មោះ Channel Telegram **"នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ"** និងព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 011 244-246 ឬលោក កែវ សីហា ទូរស័ព្ទលេខ 015 776-770 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅ ម.អ.ជ. មានទីតាំងនៅអគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ**

ELECTRICITE DU CAMBODGE

**ជុន ពិសិដ្ឋ**

ចម្លងជូន:

- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
  ដើម្បី "គោរពជូនជ្រាប"
- អគ្គនាយករងអគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ELECTRICITÉ DU CAMBODGE

Ref : 3253.EDC::REF

Phnom Penh, 24 April , 2024

# NOTICE

**Electricité du Cambodge (EDC)** honorably inform the public that under the highest consideration of improving the level of living standard of the population in rural area, RGC has the willingness to manage and strengthen the development of electricity sector in order to "reach and achieve sufficient, sustainable, reliable, quality and affordable electricity supply for all categories of consumers throughout the Kingdom of Cambodia". EDC has continuously provided grant to the Department of Rural Electrification Fund (hereinafter referred to as the "REF") in order to continuously implement **"Power to the Poor Program"**. This program is on-going program from 2013 and will also be implemented in 2024. The purpose of this program is to facilitate the poor households in rural areas to have access to electricity for their houses from licensees connected to grid supply. Under this program REF provides the electric materials for the in-house wiring and the wires from the connection point of meter to house of the rural households as donation and the rural households need to pay the costs for connection fees, deposit for the usage of electricity and labor for the installation of wires from the connection point of meter to its house and labor for the installation of in-house wiring.

In order to implement this program more effectively, Please Mr / Mrs, the electricity licensees collect the number of rural households and submit a horizontal axis (X) and a vertical axis (Y) of the digital location (WGS 1984) to REF for reviewing their eligibilities and then offering as a package. For further information, please visit our website (**www.ref.gov.kh**) and Telegram Channel "នាយកដ្ឋានមូលនិធិ អគ្គិសនីភាវូបនីយកម្មជនបទ" and / or contact Mr. Chum Chandara via 011 244-246 or Mr. Keo Seyha via 015 776-770 or REF via 023 997-600 or fax 023 997-601 or visit REF office located at building No. 205, National road No. 5, Sangkat Kilometer 6, Khan Russeykeo, Phnom Penh.

Sincerely yours,

**Mr. Chun Piseth**
Deputy Managing Director of EDC

Recipients:
- Royal Government of Cambodia Delegate in charge as Managing Director of EDC
- Electricity Authority of Cambodia for "information "
- Deputy Managing Directors of EDC
- File-Archive.